CDRI
Cambodia Development Resource Institute

សង្ខេបសម្រាប់
គោលនយោបាយ

ឆ្នាំ២០២៣ លេខ០៣

# ភាពក្រីក្រ និងវិបត្តិកូវីដ-១៩ នៅកម្ពុជា៖ បទពិសោធន៍ និងការត្រៀមខ្លួននាពេលអនាគត

## ១. សេចក្តីផ្តើម

វិបត្តិសុខភាពសកលកូវីដ-១៩ បានបង្កឱ្យមានការព្រួយបារម្ភផ្នែកសេដ្ឋកិច្ចជាបន្តបន្ទាប់។ ជំងឺនេះធ្វើឱ្យបញ្ហាដែលមានស្រាប់កាន់តែធ្ងន់ធ្ងរ និងការធ្លាក់ចុះកិច្ចខិតខំប្រឹងប្រែងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈរបកគំហើញពីការធ្លាក់ចូលក្នុងភាពក្រីក្រ និងប្រឈមភាពក្រីក្រពុំរ៉ាំរ៉ៃ។ ស្ថិតក្នុងទម្រង់រូបភាពជាច្រើន ភាពក្រីក្រ និងជំងឺកូវីដបង្កភាពតានតឹងយ៉ាងខ្លាំងលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងទំនាក់ទំនង រវាងផ្នែកកសិកម្ម ចំណាកស្រុក បំណុល ការអប់រំ និងវិស័យដទៃទៀត ឱ្យកាន់តែមានភាពប្រទាក់ក្រឡាជាងមុន។

សង្ខេបគោលនយោបាយនេះ មានបំណងស្រង់យកការសំយោគខ្លឹមសារសំខាន់ៗ ពីលទ្ធផលស្រាវជ្រាវ និងប្រធានបទសំខាន់ៗដែលលេចចេញពីការសិក្សាស្រាវជ្រាវ ក្រោមគម្រោងផ្តួចផ្តើមនៃការតាមដានភាពក្រីក្រ (PMI) ដូចជា៖ ១) *ឌីណាមិចនៃភាពក្រីក្រ និងកូវីដ-១៩ នៅកម្ពុជា* (Bird et al. 2022) និង ២) *ភាពក្រីក្រ និងសុខុមាលភាពមុន និងអំឡុងពេលមានវិបត្តិកូវីដ-១៩៖ ការវាយតម្លៃចំពោះនិន្នាការ និងភាពជាប់ទាក់ទងគ្នា* (Diwakar, Roth, and Kamninga 2022) និង *ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា៖ ដំណើរឆ្ពោះទៅការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងភាពធន់* (World Bank 2022)។

បន្ថែមលើសពីនេះទៀត មតិយោបល់ និងការពិភាក្សាគោលនយោបាយបានពីសិក្ខាសាលាពិគ្រោះយោបល់លើប្រធានបទ "ភាពក្រីក្រ និងវិបត្តិកូវីដ-១៩នៅកម្ពុជា៖ បទពិសោធន៍ និងការត្រៀមខ្លួននាពេលអនាគត" នេះ (រៀបចំឡើងនៅភ្នំពេញ ថ្ងៃទី២៣ មីនា ២០២៣) លើកយកមកពិភាក្សានៅក្នុង អត្ថបទសង្ខេបគោលនយោបាយនេះ។ វាគ្មិន និងអ្នកចូលរួមសំខាន់ៗ មានដូចជា តំណាងមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលបានអញ្ជើញចូលរួម និងចែករំលែកពីរបកគំហើញនៃការសិក្សាស្រាវជ្រាវ និងបទពិសោធន៍ការងារជាក់ស្តែង។ ប្រធានបទគន្លឹះសម្រាប់សិក្ខាសាលានេះ ផ្តោតសំខាន់លើការត្រៀមខ្លួនសម្រាប់វិបត្តិនាពេលអនាគត។

## ២. សារគោលនយោបាយជាគន្លឹះសំខាន់ៗ

### *ភាពក្រីក្រមុនពេលកូវីដ-១៩*

### *អត្រាភាពក្រីក្រក្នុងប្រទេសកម្ពុជាថ្នាក់ជាតិ ធ្លាក់ចុះខ្លាំងរហូតដល់ជិតពាក់កណ្តាលចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩*

ភាពក្រីក្រក្នុងប្រទេសកម្ពុជាថ្នាក់ជាតិ មានការធ្លាក់ចុះក្នុងរយៈពេល ១ទសវត្សរ៍ចាប់ពីចំនួន ៣៣,៨% ក្នុងឆ្នាំ២០០៩ មកដល់ចំនួន ១៧,៨% ក្នុងឆ្នាំ២០១៩/២០ (World Bank 2022)[1]។ ការវាស់វែងពីគម្លាតភាពក្រីក្រតាមរយៈគ្រួសាររស់នៅក្រោមបន្ទាត់ភាពក្រីក្រ និងតាមរយៈគម្លាតវិសមភាព ក៏បង្ហាញពីការធ្លាក់ចុះផងដែរ។ ទោះជាយ៉ាងនេះក្តី ភាពក្រីក្របន្តកើតមានលក្ខណៈខុសៗគ្នា ទៅតាមទីតាំងភូមិសាស្ត្រ និងស្ថានភាពជាក់ស្តែងនៅតាមតំបន់ជនបទក្នុងឆ្នាំ២០១៩/២០ ជាមួយអត្រាភាពក្រីក្រទូទៅចំនួន ២២,៨% ក្នុងតំបន់ជនបទ ធៀបនឹងតំបន់ទីក្រុងភ្នំពេញចំនួន ៤,២% និងចំនួន ១២,៦% ក្នុងតំបន់ប្រជុំជនដទៃទៀត។បន្ថែមលើនេះចំនួនគ្រួសារក្រីក្រប្រមូលផ្តុំខ្លាំងនៅតាមខេត្តនានាដែលស្ថិតនៅភាគពាយ័ព្យ និងភាគអាគ្នេយ៍នៃប្រទេស ដែលជាខេត្តមានល្បាយប្រជាពលរដ្ឋខ្ពស់ជាងខេត្តផ្សេងទៀត។ការបន្តរស់នៅក្នុងភាពក្រីក្រ គឺមានភាពជាប់ពាក់ព័ន្ធគ្នានឹងអត្រាអ្នកក្នុងបន្ទុក រវាងគ្រួសារមានសមាជិកពឹងផ្អែកច្រើន គ្រួសារគ្មានដីធ្លី និងគ្រួសារពឹងអាស្រ័យលើការលក់កម្លាំងពលកម្ម (Bird et al. 2022)។ ភាពជាប់ពាក់ព័ន្ធគ្នារវាងមេដឹកនាំគ្រួសារជាស្ត្រី និងភាពក្រីក្រជាទូទៅ នៅមិនទាន់ឈានដល់ការសន្និដ្ឋានជាក់លាក់ណាមួយនៅឡើយទេ។

កត្តាជំរុញមួយក្នុងចំណោមកត្តាដទៃទៀត ក្នុងការកាត់បន្ថយភាពក្រីក្រគឺ ការផ្លាស់ប្តូររចនាសម្ព័ន្ធឆ្ពោះទៅរកសមត្ថភាពផលិតខ្ពស់ជាងមុន និងវិស័យនានាដែលផ្តល់ប្រាក់កម្រៃខ្ពស់ជាងមុន ដោយកម្មករត្រូវធ្វើចំណាកស្រុកបម្លាស់ទីពីតំបន់ជនបទទៅទីក្រុង និងទីប្រជុំជននានា។ កំណើនប្រាក់ចំណូល បានពីវិស័យដែលមិនមែនកសិកម្ម បានរួមចំណែកយ៉ាងសំខាន់ និងដោយផ្ទាល់លើការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាផ្អែកលើភាពជាក់ស្តែង ចង្អុលបង្ហាញពីឥទ្ធិពលជាវិជ្ជមានគួរឱ្យកត់សម្គាល់លើការកាត់បន្ថយភាពក្រីក្រ តាមរយៈការទទួលបានការប្រើប្រាស់សេវាជាសារវន្តសម្រាប់គ្រួសាររស់នៅទីជនបទ ដូចជាការប្រើប្រាស់អគ្គិសនី សេវាទឹកស្អាតសម្រាប់បរិភោគ និងហេដ្ឋារចនាសម្ព័ន្ធ។ ការសិក្សារកឃើញបន្ថែមទៀតថា កម្រិតនៃការសិក្សាអប់រំរបស់មេគ្រួសារ និងសមាជិកគ្រួសារមានទំនាក់ទំនងជាមួយការគេចផុតពីភាពក្រីក្រ ជាពិសេសមេគ្រួសារដែលបានបញ្ចប់ការសិក្សាថ្នាក់អនុវិទ្យាល័យ ឬខ្ពស់ជាងនេះ។

### *ទោះយ៉ាងណា មានប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់បន្តរស់នៅក្បែរបន្ទាត់ភាពក្រីក្រ និងងាយរងគ្រោះក្នុងឆ្នាំ២០១៩/២០*

មានប្រជាពលរដ្ឋចំនួន ១៥% នៃប្រជាពលរដ្ឋកម្ពុជាដែលកំពុងរស់នៅ

---

រៀបរៀងដោយ ធុំ ធាវី អ្នកស្រាវជ្រាវ មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ចនិងសង្គមសម្រាប់គ្រប់គ្នានៃ វិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Chhom Theavy. 2023. *Poverty and Covid-19 in Cambodia: Lessons and Future Preparedness.* Policy Brief 2023 No. 03. Phnom Penh: CDRI.

១ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានកំណត់បន្ទាត់ភាពក្រីក្រជាតិឡើងវិញ ដោយប្រើទិន្នន័យពីរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ (CSES)។ បន្ទាត់ភាពក្រីក្រជាតិថ្មីសម្រាប់ប្រទេសកម្ពុជា គឺសំដៅលើគ្រួសារមានប្រាក់ចំណូល ១០.៩៥១រៀល/ម្នាក់/១ថ្ងៃ។ ដោយពិចារណាលើភាពខុសគ្នានៃតម្លៃរស់នៅរវាងទីតាំងផ្សេងគ្នា នេះមានន័យថា បន្ទាត់ភាពក្រីក្រជាតិមាន ១០.៩៥១រៀលនៅភ្នំពេញ ៩.៥៧១រៀលនៅតំបន់ទីក្រុងផ្សេងទៀត និង ៨.៩០៨រៀលនៅតំបន់ជនបទ។

ក្បែរបន្ទាត់ភាពក្រីក្រ និងមិនចាត់ចូលក្នុងក្រុមក្រីក្រ តែមានប្រាក់ចំណូលខ្ពស់ជាងបន្ទាត់ភាពក្រីក្របន្តិចប៉ុណ្ណោះ ក្នុងឆ្នាំ២០១៩/២០ (World Bank 2022)[២]។ ពួកគេបន្តរស់នៅក្នុងស្ថានភាពហានិភ័យ ដូច្នេះហើយ ពួកគេងាយនឹងធ្លាក់ចូលក្នុង ស្ថានភាពនៃការរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នៅពេលមានបញ្ហាប្រឈមសកលដូចជាជំងឺរាតត្បាត ឬវិបត្តិអវិជ្ជមានផ្សេងៗ។ ដូច្នេះ វាជាការចាំបាច់ក្នុងការផ្តោតការយកចិត្តទុកដាក់ និងផែនការសកម្មភាពគោលនយោបាយដោយផ្ទាល់លើគ្រួសារកំពុងរស់នៅក្បែរបន្ទាត់ក្រីក្រទាំងនោះ។

## ភាពក្រីក្រ និងវិបត្តិកូវីដ-១៩

### គ្រួសារក្រីក្រកំពុងជួបប្រទះការបាត់បង់ប្រាក់ចំណូល និងប្រឈមមុខការធ្លាក់ចុះក្នុងស្ថានភាពក្រីក្រ

វិធានការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ និងវិធានការពាក់ព័ន្ធនឹងសុខភាពសាធារណៈ បានកាត់បន្ថយប្រភពនៃការកាត់បន្ថយភាពក្រីក្រ (Bird et al. 2022)។ ការបាត់បង់ប្រាក់ចំណូលក្នុងអំឡុងពេលជំងឺរាតត្បាតកើតឡើងគ្រប់ទីកន្លែង ដោយមានការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង។ ការធ្លាក់ចុះប្រាក់ចំណូលកើតមានខ្លាំងចំពោះក្រុមដែលមានប្រាក់ចំណូលទាបជាងគេ (ក្រុមទាបជាងគេ ២០% និងក្រុមទាបបន្ទាប់ ២០%)។ យ៉ាងហោចណាស់ មានគ្រួសារក្រីក្រ ៨៣% នៃគ្រួសារក្រីក្របានរាយការណ៍ពីការធ្លាក់ចុះប្រាក់ចំណូល ក្នុងខែឧសភា ឆ្នាំ២០២០ ដោយធ្លាក់ចុះមកនៅត្រឹម ៤៤% ក្នុងខែមីនា ឆ្នាំ២០២១ ដូច្នេះទិន្នន័យនេះបង្ហាញថា ស្ថានភាពប្រាក់ចំណូលនៃគ្រួសារក្រីក្រមានភាពល្អប្រសើរជាងមុន ប៉ុន្តែនៅមិនទាន់ត្រលប់មករកសភាពដើមនៅឡើយទេ។ ការបាត់បង់ប្រាក់ចំណូលបន្តស្ថិតនៅក្នុងសភាពធ្ងន់ធ្ងរនៅឡើយ គិតត្រឹមខែមីនា ឆ្នាំ២០២១ ដោយទិន្នន័យបានចង្អុលបង្ហាញពីការធ្លាក់ចុះប្រាក់ចំណូលសម្រាប់គ្រួសារដែលក្រីក្រស្រាប់ (Diwakar, Roth, and Kamninga 2022)។ ការប្រកបរបរចិញ្ចឹមជីវិតច្រើនមុខបានផ្តល់ភាពធន់ក្នុងអំឡុងពេលជំងឺរាតត្បាត ហើយគ្រួសារប្រកបរបរចិញ្ចឹមជីវិតច្រើនមុខ មិនសូវងាយរងគ្រោះធ្លាក់ចូលក្នុងភាពក្រីក្រ និងភាពក្រីក្ររ៉ុាំរ៉ៃ (Bird et al. 2022)។

### ជំងឺរាតត្បាតបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដល់ការប្រកបរបរចិញ្ចឹមជីវិតលើវិស័យកសិកម្ម

ការប្រកបរបរចិញ្ចឹមជីវិតលើផ្នែកកសិកម្ម មានប្រវត្តិយ៉ាងជិតស្និទ្ធជាមួយការធ្វើចំណាកស្រុក ដោយគ្រួសារកសិករដែលពឹងផ្អែកលើប្រាក់ផ្ញើមកផ្ទះសម្រាប់ធ្វើជាដើមទុនក្នុងការធ្វើកសិកម្ម។ ការរំខានដល់ការធ្វើចំណាកស្រុកក្នុងអំឡុងពេលជំងឺរាតត្បាត បង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងលើស្ថានភាពជំពាក់បំណុល ដោយសារគ្រួសារកសិករបន្តខិតខំធ្វើយ៉ាងណា ឱ្យការងារស្រែចម្ការរបស់ពួកគេ បន្តដំណើរការ។ ការកើនឡើងតម្លៃដើមនៃកសិកម្ម (ឧទាហរណ៍ ថ្នាំសម្លាប់សត្វល្អិត ប្រេង និងជីកសិកម្ម អំឡុងពេលរំខានពីជំងឺរាតត្បាតលើខ្សែសង្វាក់ផលិតកម្មកសិកម្ម) បង្កឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានភាពបំណុលកាន់តែច្រើន ហើយគ្រួសារមួយចំនួន សម្រេចចិត្តបោះបង់ចោលដីស្រែរបស់ពួកគេ (Bird et al. 2022)។ សូម្បីតែគ្រួសារមានជីវភាពល្អប្រសើរ ក៏ប្រឈមនឹងវិបត្តិធ្ងន់ធ្ងរ និងពិបាកយកឈ្នះលើបញ្ហាដែលបង្កឡើងដោយជំងឺរាតត្បាត។

ការកាត់បន្ថយតម្រូវការកម្លាំងពលកម្ម ព្រមទាំងការកាត់បន្ថយប្រាក់ឈ្នួលបានពីការលក់កម្លាំងពលកម្ម បានបង្កឱ្យប្រជាពលរដ្ឋក្រីក្រ និងគ្រួសារដែលគ្មានដីធ្លី នៅមុនពេលមានជំងឺរាតត្បាតនោះ កាន់តែទទួលរងគ្រោះខ្លាំងជាងមុន។ ក្នុងអំឡុងពេលមានការផ្ទុះជំងឺរាតត្បាត គ្រួសារកសិករខ្នាតមធ្យម បានបង្កើតយុទ្ធសាស្ត្រជួយគ្នាទៅវិញទៅមកក្នុងចំណោមក្រុមមនុស្សជិតស្និទ្ធ ដោយបញ្ឈប់ការជួលកម្លាំងពលកម្មពីគ្រួសារក្រីក្រសម្រាប់ដីស្រែចម្ការរបស់ពួកគេ។

ផលប៉ះពាល់ពីជំងឺរាតត្បាតលើការបាត់បង់ប្រាក់ចំណូល បង្កផលប៉ះពាល់យ៉ាងខ្លាំង ដល់អ្នកលក់បន្លែចល័តតាមដងផ្លូវ បើធៀបនឹងកម្មករចំណាកស្រុកក្នុងវិស័យកាត់ដេរ និងសំណង់។ ទាំងនេះដោយសារអ្នកលក់បន្លែ ពឹងអាស្រ័យលើកម្មករជាអ្នកទិញបន្លែរបស់ពួកគេ ប៉ុន្តែកម្មករទាំងនោះចាប់ផ្តើមទិញជឿ និងមិនមានលទ្ធភាពសងថ្លៃជំពាក់។

### ការអាក់ខានក្នុងការរៀនសូត្រ និងការកើនឡើងការបោះបង់ចោលការសិក្សា

ផលវិបាកសំខាន់មួយបណ្តាលមកពីជំងឺរាតត្បាត គឺការបាត់បង់ការសិក្សាអប់រំ។ បញ្ហានេះគឺជាការព្រួយបារម្ភដ៏ចម្បង ដោយសារការសិក្សាអប់រំកម្រិតអនុវិទ្យាល័យ ឬខ្ពស់ជាងនេះ បានជួយគាំពារគ្រួសារឱ្យគេចផុតពីភាពក្រីក្រនៅមុនពេលមានជំងឺរាតត្បាត។

អំឡុងពេលជំងឺរាតត្បាត ការអាក់ខានក្នុងការរៀនសូត្រ កើតមានគ្រប់ទីកន្លែង និងផ្តល់ផលប៉ះពាល់ដល់កុមារក្រីក្ររស់នៅតាមជនបទយ៉ាងខ្លាំង។ កុមារជាច្រើនមិនបានទទួលការសិក្សាអប់រំក្នុងអំឡុងពេលមានការបិទសាលារៀន ដោយសារតែឪពុកម្តាយរបស់ពួកគេមិនមានទូរស័ព្ទស្មាតហ្វូន ឬមិនមានលទ្ធភាពផ្គត់ផ្គង់ថ្លៃសេវាប្រើប្រាស់អ៊ីនធឺណិត។ កុមារជាច្រើនជួបការលំបាក ក្នុងការផ្តោតអារម្មណ៍ទៅលើមេរៀន តាមរយៈការបង្រៀនតាមប្រព័ន្ធទូរស័ព្ទដៃ ហើយឪពុកម្តាយរបស់ពួកគេជាញឹកញាប់ មិនបានជួយកូនតាមរយៈការសិក្សានៅផ្ទះទេ ដោយសារតែពួកគេរវល់ធ្វើការចិញ្ចឹមជីវិត។ ទោះបីសាលារៀនបានបើកដំណើរការឡើងវិញក៏ដោយ ការចូលរៀនរបស់កុមារពីគ្រួសារក្រីក្រនៅតែមានកម្រិតទាប ដោយសារពួកគេមួយចំនួនបានសម្រេចចិត្តបោះបង់ចោលការសិក្សា ហើយធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ (Bird et al. 2022)។ ទិន្នន័យនាពេលថ្មីៗចង្អុលបង្ហាញពីការកើនឡើងនៃចំនួនកុមារ កំពុងចូលរួមកម្លាំងពលកម្មក្នុងការងារក្នុងខែកក្កដា ឆ្នាំ២០២១ បើធៀបនឹងខែមីនា ឆ្នាំ២០២១ (Diwakar, Roth, and Kamninga 2022)។

ការវិភាគលើការខាតបង់និងផលចំណេញ ឬការសម្រេចចិត្តដែលធ្វើឱ្យមានតុល្យភាពរវាងវិធានការសុខភាព ការបិទសាលារៀន និងផលប៉ះពាល់សេដ្ឋកិច្ច-សង្គមផ្សេងទៀត គឺមានសារៈសំខាន់ណាស់ ក្នុងការផ្តល់ជាព័ត៌មានដល់ការសម្រេចចិត្ត ទាក់ទងនឹងហានិភ័យនាពេលអនាគត។

### ការខ្ចីប្រាក់ជាយុទ្ធសាស្ត្រដោះស្រាយទប់ទល់ជាមួយផលអវិជ្ជមាន

គ្រួសារជាច្រើន បានបង្ខំចិត្តរស់នៅ ពឹងផ្អែកលើយុទ្ធសាស្ត្រដោះស្រាយជីវភាពជាច្រើន ដែលបង្កផលអវិជ្ជមាន ជាពិសេសការកាត់បន្ថយការបរិភោគអាហារប្រចាំថ្ងៃ និងការចំណាយការចូលរួមសកម្មភាពសង្គម ដូចជា ការចូលរួមពិធីមង្គលការ ការផ្លាស់ប្តូរសាលារៀនរបស់កូនទៅ សាលារៀនណាដែលបង់ថ្លៃទាបជាងមុន និងការធ្វើចំណាកស្រុកពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ដើម្បីស្វែងរកប្រាក់ចំណូល និងការងារ។ តាមការវិភាគដោយផ្អែកលើយេនឌ័រ

២ ប្រជាពលរដ្ឋរស់នៅក្បែរបន្ទាត់ភាពក្រីក្រត្រូវបានកំណត់ថា ជាប្រជាពលរដ្ឋផ្អែកលើការវាស់វែងការប្រើប្រាស់ប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ (per capita daily consumption) ស្ថិតនៅចន្លោះបន្ទាត់ភាពក្រីក្រ និងចំនួន ១,២៥ ដងនៃបន្ទាត់ភាពក្រីក្រ។

គ្រួសារដែលដឹកនាំដោយស្ត្រីជាមេគ្រួសារ មុខជាទៅស្វែងរកការពឹងផ្អែកការគាំទ្រ ដូចជា រឿងអាហារហូបចុកជាដើមពីមិត្តភ័ក្តិនៅពេលចាប់ផ្តើមនៃជំងឺរាតត្បាត បើធៀបនឹងគ្រួសារដែលដឹកនាំដោយបុរសជាមេគ្រួសារ (Diwakar, Roth, and Kamninga 2022)។

ការសិក្សាស្រាវជ្រាវបានបង្ហាញបន្ថែមទៀតថា ការខ្ចីប្រាក់បន្ថែមជាយុទ្ធសាស្ត្រសំខាន់ក្នុងចំណោមគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ ដើម្បីទប់ទល់នឹងជំងឺរាតត្បាត និងការបាត់បង់ប្រាក់ចំណូលភ្លាមៗ។ ការកើនឡើងក្នុងការខ្ចីប្រាក់ចំពោះគ្រួសារក្រីក្រ គឺជាដំណោះស្រាយរយៈពេលខ្លីតែប៉ុណ្ណោះ ដែលអាចបន្សល់ទុកនូវផលប៉ះពាល់អវិជ្ជមានក្នុងរយៈពេលយូរ។ ការកើនឡើងនៃការជំពាក់បំណុល ផ្តល់ផលប៉ះពាល់ដល់ការបរិភោគអាហារ និងអាហារូបត្ថម្ភរបស់គ្រួសារ និងជំរុញឱ្យមានការធ្វើចំណាកស្រុក និងជំរុញឱ្យកុមារពីគ្រួសារក្រីក្របោះបង់ការសិក្សាកាន់តែច្រើន។ ផលប៉ះពាល់ដែលផ្តល់ផលអាក្រក់ជាងនេះ អាចពិបាកក្នុងការធ្វើការសង្កេត ហើយអាចត្រូវការពេលវេលាដើម្បីធ្វើការសិក្សា។ ផលប៉ះពាល់ទាំងនេះ គួរឱ្យកត់សម្គាល់រាប់បញ្ចូលទាំងការលក់ដីធ្លី នេះបើយោងទៅតាមលទ្ធផលការសិក្សាស្រាវជ្រាវមួយ (Bird et al. 2022)។

### *ការពង្រីកប្រព័ន្ធកិច្ចគាំពារសង្គម ដើម្បីបន្ធូរបន្ថយផលប៉ះពាល់លើប្រាក់ចំណូល ជាមួយគុណវិបត្តិមួយចំនួន*

ប្រទេសកម្ពុជា មានភាពខុសប្លែកពីគេក្នុងចំណោមប្រទេសដែលមានប្រាក់ចំណូលទាប ឬមធ្យម (LMICs) ទាក់ទងនឹងការដាក់ចេញវិធានបន្ធូរបន្ថយផលប៉ះពាល់ដល់សុខភាពសាធារណៈ ដែលមិនសូវប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ កម្មករក្នុងវិស័យកាត់ដេរ និងទេសចរណ៍ បានទទួលអត្ថប្រយោជន៍ពីការព្យួរការងារ បន្ថែមលើអត្ថប្រយោជន៍ ទទួលបានពីការគាំពារសង្គម និងយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់ (Bird et al. 2022)។

កម្មវិធីបណ្ណក្រីក្រ/បណ្ណសមធម៌ បានចាប់ផ្តើមពីឆ្នាំ២០០៦ និងបន្តអនុវត្តរហូតមកដល់សព្វថ្ងៃនេះ តាមរយៈការផ្តល់សេវាកម្ម និងជំនួយសង្គមដល់គ្រួសារក្រីក្រខ្លាំង និងក្រុមងាយរងគ្រោះ តាមរយៈការជួយពីរាជរដ្ឋាភិបាល និងអង្គការផ្សេងៗ។ គ្រួសារដែលមានបណ្ណសមធម៌ ទទួលបានសេវាថែទាំសុខភាពសាធារណៈដោយឥតគិតថ្លៃ និងកិច្ចគាំពារសង្គមពីរដ្ឋាភិបាល (ឧទាហរណ៍ កម្មវិធីផ្តល់សាច់ប្រាក់) អាហារូបករណ៍ អាហារនៅសាលាបឋមសិក្សា ការអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ អគ្គិសនី ការដំឡើងប្រព័ន្ធទឹកស្អាត និងឧបករណ៍កសិកម្ម។

កម្មវិធីផ្តល់សាច់ប្រាក់ផ្តល់ជូន គ្រួសារងាយរងគ្រោះបំផុត ដែលរងផលប៉ះពាល់ដោយវិបត្តិផ្សេងៗគ្នា ផ្ទួនៗគ្នា ដូចជាផលប៉ះពាល់ពីការបិទខ្ទប់ ជំងឺរាតត្បាត ទឹកជំនន់ និងអតិផរណា។ កម្មវិធីផ្តល់សាច់ប្រាក់បានទៅដល់គ្រួសារក្រីក្រ ដែលមានបណ្ណសមធម៌ជាច្រើនជាបន្តបន្ទាប់។ ទោះជាសុខុមាលភាពមានភាពប្រសើរឡើងក៏ដោយ ការផ្តល់សាច់ប្រាក់នេះមិនគ្រប់គ្រាន់ទេ ជាហេតុនាំឱ្យបញ្ហាអសន្តិសុខស្បៀងបន្តកើតមាន។

ការសិក្សាបង្ហាញពីភាពខុសគ្នា ទៅតាមតំបន់ទាក់ទងនឹងវិសាលភាពគ្របដណ្តប់របស់ប្រព័ន្ធកិច្ចគាំពារសង្គម ដោយតំបន់បឹងទន្លេសាបនៅចាត់ចូលជាតំបន់មានលក្ខខណ្ឌមិនអំណោយផល ក្នុងការទទួលបានអត្ថប្រយោជន៍នេះ។ ការសិក្សាក៏បង្ហាញពីបញ្ហាកើតមានជាមួយនឹងការកំណត់គោលដៅសម្រាប់ក្រុមទទួលបានអត្ថប្រយោជន៍ និងភាពមិនលម្អៀងនៅមានកម្រិតក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដែលធ្វើឡើងដោយថ្នាក់ដឹកនាំមូលដ្ឋានក្នុងសហគមន៍មួយចំនួន។

## ៣. សារជាគន្លឹះសំខាន់ៗ

ដូចដែលបានបង្ហាញក្នុងលទ្ធផលស្រាវជ្រាវ និងការពិភាក្សាក្នុងសិក្ខាសាលាមានចំណុចមួយចំនួនចាំបាច់ទាមទារ ឱ្យធ្វើការវិភាគឡើងវិញក្នុងការបង្កើនភាពធន់ និងការត្រៀមខ្លួនសម្រាប់វិបត្តិនាពេលអនាគត។ ចំណុចទី១ ការអនុវត្តកម្មវិធីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្របង្កឧបសគ្គមួយចំនួន សម្រាប់គ្រួសាររស់នៅក្បែរបន្ទាត់ភាពក្រីក្រ ដែលគេបានចាត់ទុកថាមិនមែនជាគ្រួសារក្រីក្រ។ ពួកគាត់មានតម្រូវការដូចគ្នានឹងគ្រួសារស្ថិតក្នុងតំបន់គោលដៅ សម្រាប់កម្មវិធីគ្រួសារក្រីក្រនោះដែរ។ ទោះបីពួកគាត់ស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ គ្រួសារទាំងនោះមិនទទួលបានវគ្គបណ្តុះបណ្តាល ឬការគាំទ្រផ្សេងទៀតនោះទេ ដោយហេតុថាពួកគាត់មិនមែនជាជនគោលដៅសម្រាប់កម្មវិធី។

ចំណុចទី២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចាំបាច់ធ្វើការវាយតម្លៃឡើងវិញប្រកបដោយការប្រុងប្រយ័ត្ន ចំពោះសមត្ថភាពសងបំណុលរបស់អ្នកខ្ចីបុលក្នុងស្រុកទាំងអស់នោះ និងជៀសវាងការផ្តល់ប្រាក់កម្ចីដែលមានលក្ខណៈងាយស្រួលពេក ដែលអាចធ្វើឱ្យមានគុណវិបត្តិច្រើនជាងគុណសម្បត្តិសម្រាប់អ្នកខ្ចីបុលទាំងនោះ។ ធនាគារជាតិនៃកម្ពុជា បានអនុវត្តគោលការណ៍ហិរញ្ញវត្ថុមួយចំនួន រួមមានការកំណត់ពិដានអត្រាការប្រាក់ឥណទាន ការបង្កើតខ្សែទូរស័ព្ទទទួលបណ្តឹងពីអ្នកប្រើប្រាស់ ជាពិសេសការចេញសារាចរថ្មី ដែលអនុញ្ញាតឱ្យអ្នកខ្ចីបុលស្នើសុំរៀបចំឥណទានសាជាថ្មី ដើម្បីកាត់បន្ថយបន្ទុកហិរញ្ញវត្ថុរបស់អ្នកខ្ចីបុលក្នុងអំឡុងពេលវិបត្តិកូវីដ។ ទន្ទឹមនឹងនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានដាក់ចេញនូវក្រមប្រតិបត្តិលើការអនុវត្តបទប្បញ្ញត្តិដោយខ្លួនឯង ជាពិសេស គោលការណ៍ការពារអតិថិជន និងវិធានផ្តល់ឥណទាន។ ទោះយ៉ាងណា ការអនុវត្តវិធានការអនុវត្តបទប្បញ្ញត្តិដោយខ្លួនឯង ជាទូទៅមិនបានការពារអ្នកខ្ចីប្រាក់កម្ពុជាឡើយ (Bliss 2022)។

ចំណុចទី៣ ផលវិបាកមិនបានរំពឹងទុក ពីការអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ ចំពោះគ្រួសាររងប៉ះពាល់ ដោយសារអតិផរណា និងដោយសារទឹកជំនន់ ចាំបាច់ទាមទារឱ្យមានផែនការឱ្យបានល្អសម្រាប់ពេលអនាគត។ ចំពោះគ្រួសារដែលមិនមែនជាក្រុមគោលដៅរបស់កម្មវិធីផ្តល់សាច់ប្រាក់យល់ឃើញថា ពួកគេរងផលប៉ះពាល់ខ្លាំង ប៉ុន្តែទទួលបានការជួយគាំទ្រតិចតួចបំផុតពីរាជរដ្ឋាភិបាលកម្ពុជា។

ជំងឺរាតត្បាតកូវីដ-១៩ ផ្តល់ជាសញ្ញាពីតម្រូវការដ៏ចាំបាច់ លើវិធីសាស្ត្រមួយដែលយកមតិប្រជាពលរដ្ឋជាធំ។ ដូច្នេះទស្សនៈផ្សេងៗគ្នា និងការចូលរួមពីតួអង្គសំខាន់ៗនៅក្នុងការសម្រេចចិត្ត និងការអនុវត្តការសម្រេចចិត្តមានសារៈសំខាន់ណាស់។ ដូចគ្នានេះដែរ គឺការបញ្ចេញសំឡេងនិងមតិយោបល់របស់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ។ នេះមានន័យថា រដ្ឋាភិបាលថ្នាក់មូលដ្ឋានមានតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងការចូលរួមនិងការរួមចំណែកនៅថ្នាក់មូលដ្ឋាន ព្រោះជាធម្មតារដ្ឋាភិបាលថ្នាក់មូលដ្ឋាន ទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយជាង អំពីតម្រូវការនិងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋខ្លួន។

កង្វល់ និងសំណើសំខាន់ៗដែលបានបង្ហាញក្នុងសិក្ខាសាលា៖

*ប្រជាពលរដ្ឋក្រីក្រប្រឈមនឹងភាពងាយរងគ្រោះកាន់តែខ្លាំង*៖ ភាពងាយរងគ្រោះដែលមានស្រាប់ដូចជា បញ្ហាបំណុល ជំងឺរុំរ៉ៃ និងការទទួលបានប្រាក់ចំណូលទាប នៅតែបន្តជាបញ្ហាប្រឈមក្នុងចំណោមគ្រួសារក្រីក្រ។ បញ្ហាទាំងនេះ កាន់តែមានភាពធ្ងន់ធ្ងរដោយសារជំងឺរាតត្បាតកូវីដ-១៩ ដែលបានបណ្តាលឱ្យជីវភាពរស់នៅពួកគេកាន់តែប្រឈមខ្លាំងឡើង។ ដោយសារក្រុមគ្រួសារដែលងាយរងគ្រោះពិបាកក្នុងការស្តារជីវភាពឡើងវិញ ពួកគេមានការព្រួយបារម្ភយ៉ាងខ្លាំង ខ្លាចកម្មវិធីផ្តល់សាច់ប្រាក់ ត្រូវបានបញ្ឈប់ និងមិនបន្តការផ្តល់សាច់ប្រាក់ជូនពួកគេ ដូចដែលរបាយការណ៍ដោយអាជ្ញាធរមូលដ្ឋានថ្នាក់ឃុំ និង

ក្រុមប្រឹក្សាឃុំនៅក្នុងសិក្ខាសាលា។ ការព្រួយបារម្ភនេះ គឺស្របទៅនឹងការសង្កត់ធ្ងន់របស់ធនាគារពិភពលោក លើហានិភ័យនៃភាពក្រីក្រក្នុងរយៈពេលវែង បើទោះបីជាសេដ្ឋកិច្ចងើបឡើងវិញក៏ដោយ។

*កម្មករកាត់ដេរត្រូវការការគាំទ្ររយៈពេលវែង*៖ តម្រូវការការគាំទ្ររយៈពេលវែងសម្រាប់វិស័យកាត់ដេរ ព្រោះវិស័យនេះបានប្រឈមនឹងភាពងាយរងគ្រោះរួចមកហើយបណ្តាលមកពីការរំខានខ្សែសង្វាក់ផ្គត់ផ្គង់សកល។ បទសម្ភាសន៍បែបគុណវិស័យមួយបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងភ្នំពេញ លើកឡើងពីការព្រួយបារម្ភចំពោះចំនួនរោងចក្របន្តការបិទទ្វារ។

*បញ្ហាប្រឈមតាមវិស័យសំខាន់ៗ*៖ មេឃុំ និងក្រុមប្រឹក្សាឃុំ បានចង្អុលបង្ហាញពីតម្រូវការ សម្រាប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងការកសាងប្រព័ន្ធធារាសាស្ត្របន្ថែមទៀត សម្រាប់កសិករតាមជនបទ។ វគ្គបណ្តុះបណ្តាលកសិកម្ម បច្ចុប្បន្ន ដោយមានបញ្ហាកង្វះបុគ្គលិកបច្ចេកទេសកសិកម្ម ពុំសូវជាបានឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋឡើយ។ ចំណុចទីពីរ ជម្លោះកើតឡើងរវាងអ្នកខ្ចីបុល និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការផ្តល់ប្រាក់កម្ចីងាយស្រួលពេក ទាមទារការគ្រប់គ្រងឱ្យបានល្អ ដោយផ្អែកលើការវាយតម្លៃតឹងរឹងលើសមត្ថភាពសងបំណុលរបស់អ្នកខ្ចីបុល។ ចំណុចទីបី មានការព្រួយបារម្ភអំពីការបោះបង់ការសិក្សាក្នុងចំណោមកុមារដែលមួយផ្នែកមកពីការរងសម្ពាធសេដ្ឋកិច្ចគ្រួសារមកលើពួកគេ ជាហេតុនាំឱ្យពួកគេចាំបាច់ចូលរួមក្នុងការបង្កើតប្រាក់ចំណូលក្នុងគ្រួសារក្នុងអំឡុងពេលជំងឺរាតត្បាត។

*តម្រូវការវិធីសាស្ត្របង្ការទុកជាមុនបន្ថែមទៀត*៖ ក្រសួងផែនការបានគូសបញ្ជាក់ថា ការស្រាវជ្រាវគួរតែផ្តោតលើអ្វីដែលត្រូវធ្វើបន្ថែមទៀតនាពេលអនាគត ដោយសារកន្លងមករដ្ឋាភិបាលកម្ពុជាបានឆ្លើយតបចំពោះបញ្ហា ដោយទទួលបានលទ្ធផលវិជ្ជមានរួចទៅហើយ ក្នុងការបន្ធូរបន្ថយផលប៉ះពាល់នៃការរឹតបន្តឹង ដែលបានដាក់ចេញនៅអំឡុងពេលជំងឺរាតត្បាត។ តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) បានសង្កត់ធ្ងន់លើវិធីសាស្ត្របច្ចុប្បន្នចំពោះជំងឺរាតត្បាត មាននិន្នាការផ្តោតលើវិធីសាស្ត្រឆ្លើយតប។ វិធីសាស្ត្របង្ការទុកជាមុនគួរជាវិធានការសំខាន់ ដើម្បីជៀសវាងការលំបាក ដែលប្រជាពលរដ្ឋកម្ពុជាធម្មតាបានជួបប្រទះ និងការពង្រីកវិសាលភាពការទទួលបានការធានារ៉ាប់រងគ្រោះមហន្តរាយ ក្នុងចំណោមគ្រួសារក្រីក្រដូចដែលមានចែងនៅក្នុង ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ (RGC 2019)។

*ហានិភ័យនៃភាពក្រីក្រអូសបន្លាយ បើទោះបីជាមានការងើបឡើងវិញខាងវិស័យសេដ្ឋកិច្ចក៏ដោយ*៖ ធនាគារពិភពលោក និងក្រុមអ្នកស្រាវជ្រាវ CDRI បានលើកឡើងពីការព្រួយបារម្ភអំពីហានិភ័យនៃភាពក្រីក្រក្នុងសភាពអូសបន្លាយ ទោះបីជាមានការងើបឡើងវិញនៃសេដ្ឋកិច្ចក៏ដោយ មួយផ្នែកដោយសារវិសមភាពក្នុងការអភិវឌ្ឍតាមតំបន់។ កម្មវិធីផ្តល់សាច់ប្រាក់បច្ចុប្បន្នគឺពិតជាចាំបាច់សម្រាប់គ្រួសារក្រីក្រ ប៉ុន្តែវាមិនគ្រប់គ្រាន់សម្រាប់ពួកគាត់ឡើយ។ គ្រួសារក្រីក្របានបង្កើតយុទ្ធសាស្ត្រទប់ទល់ដោយខ្លួនឯង ដោយត្រូវប្រឈមនឹងផលប៉ះពាល់អវិជ្ជមានរយៈពេលវែង លើជីវភាពរស់នៅរបស់ពួកគេ ដូចជាការស្វែងរកប្រាក់កម្ចីជាមួយនឹងអត្រាការប្រាក់ខ្ពស់កាន់តែច្រើន ពីកម្ចីផ្លូវការ និងមិនផ្លូវការ។

## ៤. អនុសាសន៍គោលនយោបាយ

ផលប៉ះពាល់នៃជំងឺរាតត្បាត បង្កបញ្ហាធ្ងន់ធ្ងរបន្ថែមទៀតលើវិបត្តិផ្សេងទៀត ជាមួយនឹងផលប៉ះពាល់អវិជ្ជមានជាច្រើនលើវិស័យ ដូចជា៖ វិស័យសុខភាព វិស័យអប់រំ វិស័យសេវាកម្មហិរញ្ញវត្ថុ ជាពិសេសមីក្រូហិរញ្ញវត្ថុ វិស័យកសិកម្ម វិស័យសេដ្ឋកិច្ច និងវិស័យកាត់ដេរ។ អនុសាសន៍គោលនយោបាយជាក់លាក់ដកស្រង់ចេញពី គម្រោងគំនិតផ្តួចផ្តើមត្រួតពិនិត្យភាពក្រីក្រ (PMI) មានគោលបំណងសំខាន់ដើម្បីបង្ការការកើតឡើងភាពក្រីក្រ និងដោះស្រាយភាពក្រីក្ររ៉ាំរ៉ៃ ដែលអាចយកមកពិចារណាសម្រាប់ត្រៀមខ្លួននាពេលអនាគតដូចខាងក្រោម៖

- អភិវឌ្ឍកសិកម្មឆ្លាតវៃ និងពឹងផ្អែកតិចតួចលើសារធាតុគីមីសម្រាប់កសិផល និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព រួមបញ្ចូលទាំងការពង្រីកប្រព័ន្ធធារាសាស្ត្រ ការវិនិយោគ និងលើកកម្ពស់ការកែច្នៃកសិផលក្នុងស្រុក។
- បង្កើតវិសាលភាពគ្របដណ្តប់លើប្រព័ន្ធកិច្ចគាំពារសង្គម ឱ្យបានទូលំទូលាយ និងឱ្យបានគ្រប់គ្រាន់ ជាពិសេស សម្រាប់គ្រួសារក្រីក្រដែលជាទូទៅចូលរួមពាក់ព័ន្ធក្នុងវិស័យការងារក្រៅផ្លូវការ សម្រាប់ជាមធ្យោបាយមួយដើម្បីកាត់បន្ថយហានិភ័យផ្នែកសេដ្ឋកិច្ច និងសុខភាព។ ឧទាហរណ៍ ទោះបីជំនួយសង្គមពីរដ្ឋាភិបាល នៅមិនទាន់គ្រប់គ្រាន់ក៏ដោយ ក៏គួរតែបន្តរហូតទាល់តែកម្មវិធីផ្ទេរធនធាន និងជំនាញត្រូវបានអនុវត្តបានល្អ។
- ដាក់ចេញបទប្បញ្ញត្តិហិរញ្ញវត្ថុបន្ថែមទៀត ពិសេសទៅលើការអនុវត្តនាពេលបច្ចុប្បន្ន ក្នុងការផ្តល់ប្រាក់កម្ចីងាយស្រួលពេក ដែលជាការចាំបាច់ ដើម្បីការពារប្រជាពលរដ្ឋពីការជំពាក់បំណុលគេ។ បទប្បញ្ញត្តិហិរញ្ញវត្ថុនេះ អាចជាការកែទម្រង់ និងគ្រប់គ្រងគុណភាពនៃសេវាកម្មហិរញ្ញវត្ថុ។
- ការកសាងសមត្ថភាព ដើម្បីផ្តល់ ជំនាញបច្ចេកទេសត្រឹមត្រូវ ចំណេះដឹង និងការគ្រប់គ្រងហានិភ័យ ដែលទាក់ទងនឹងគ្រោះមហន្តរាយ និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ គឺចាំបាច់សម្រាប់ផ្តល់ឱ្យទាំងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងប្រជាពលរដ្ឋ។
- ការវិភាគលើការខាតបង់ និងផលចំណេញ ឬការវិភាគលើការសម្រេចចិត្តដែលធ្វើឱ្យមានតុល្យភាព រវាងការសម្រេចចិត្តបិទសាលារៀននៅកម្ពុជា និងការបាត់បង់ការអប់រំនិងការសិក្សា និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គមផ្សេងទៀត គឺមានសារៈសំខាន់ណាស់ក្នុងការផ្តល់ជាព័ត៌មាន សម្រាប់ការសម្រេចចិត្តទាក់ទងនឹងហានិភ័យ សម្រាប់ជំងឺរាតត្បាតនាពេលអនាគត។ ការសិក្សានេះបានរកឃើញថា ការប្តូរការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត និងការរៀនពីចម្ងាយ ជះឥទ្ធិពលអវិជ្ជមានខ្លាំងដល់កុមារក្រីក្រនៅតាមជនបទ ដោយសារគ្រួសារពួកគេខ្វះខាតធនធាន និងវិសមភាពនៃការទទួលបានសេវាអ៊ីនធឺណិត ប្រើប្រាស់ រវាងទីក្រុង និងជនបទ ជាពិសេសនៅតំបន់ដាច់ស្រយាល។
- បន្តការធ្វើឱ្យប្រសើរឡើងនូវធនធានមនុស្ស តាមរយៈការវិនិយោគបន្ថែមលើវិស័យសុខាភិបាល និងការអប់រំ។ ប្រព័ន្ធថែទាំសុខភាពចាំបាច់មានការកែលម្អឱ្យបានប្រសើរជាងមុន ទាំងគុណភាពនៃសេវាកម្មនិងសមត្ថភាពរបស់អ្នកផ្តល់សេវាកម្មនិងត្រូវមានការផ្តល់ហិរញ្ញប្បទានសុខភាពបន្ថែមទៀត។ ជាពិសេស ការពង្រីកការគ្របដណ្តប់ច្រើនលើ ការទទួលបានសេវាសុខភាពមូលនិធិសមធម៌សុខភាព (HEFs) ជួយធ្វើឱ្យប្រសើរឡើងលទ្ធភាពទទួលបានការថែទាំសុខភាពប្រសើរជាងមុនរបស់គ្រួសារក្រីក្រ។
- ការគ្រប់គ្រងវិបត្តិតាមរយៈ កម្មវិធីផ្តល់សាច់ប្រាក់ចំពោះគ្រួសាររងផលប៉ះពាល់ដោយសារទឹកជំនន់ និងអតិផរណាចាំបាច់ត្រូវរៀបចំឱ្យបានល្អដោយផ្អែកលើហានិភ័យ និងការចែករំលែកអត្ថប្រយោជន៍សម្រាប់គ្រួសារ និងបុគ្គលដែលប្រឈមនឹងហានិភ័យខ្ពស់ តែមិនស្ថិតនៅក្នុងក្រុមគោលដៅរបស់កម្មវិធី។